**ករណីសិក្សា**

# ភ្នំជិនក្រុមសន្សំតំបន់ទល់ដែន

ភ្នំជិនខាងជើងជាភូមិមួយដែលស្ថិតនៅព្រំប្រទល់កម្ពុជា-វៀតណាម។ ក្រុមសន្សំប្រាក់នេះបានកើតឡើងដោយមានការសម្របសម្រួលពីអង្គការភីស៊ី។ សមាជិកក្រុមសន្សំចំនួន១៨នាក់ស្រី



ទាំងអស់។ ក្រុមនេះបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២។ ការបង្កើតឡើងនេះក្នុងគោលបំណងចង់ឲ្យសមាជិកទាំងអស់មានគំនិតនិងចេះសន្សំប្រាក់និងពួកគេអាចខ្ចីប្រាក់ទាំងនេះទៅប្រកបមុខរបរចិញ្ចឹមជីវិត។

ក្រុមនេះបានកំណត់ដាក់ទុនពី ៥,០០០ ទៅ១០,០០០រៀលសម្រាប់មួយភាគហ៊ុន ហើយសមាជិកម្នាក់ៗអាចដាក់ភាគហ៊ុនបានលើពីនេះតាមលទ្ធភាពដែលពួកអាចធ្វើបាន និងបានឯកភាពគ្នាយកការប្រាក់ត្រឹមតែ២ភាគរយ។

មកដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ក្រុមសន្សំដាក់ទុនបានចំនួន៧៨,៥០០០រៀល និងការប្រាក់បានចំនួន៥៨,០០០រៀល។ សមាជិកទាំងអស់មាចិត្តសប្បាយរីករាយជាខ្លាំង ដោយពួកគេបានមើលឃើញពីការរីកចម្រើន និងមានជំនឿនៅក្នុងក្រុម ព្រមទាំងបានដឹងពីវិធីនិងផលប្រយោជន៍នៃការសន្សំប្រាក់។ តាមសម្ដីរបស់បងស្រី **នុន សុខសីន** រស់នៅភូមិភ្នំជិន ឃុំភ្នំជិន ស្រុកគិរីវង់ ខេត្តតាកែវ ជាប្រធានក្រុមសន្សំបានឲ្យដឹងថា៖ សមាជិករបស់ក្រុមទាំងអស់មានចិត្តសប្បាយរីករាយនិងពេញចិត្តចូលរួមក្រុមសន្សំប្រាក់ ពីព្រោះពួកគេបានយល់ពីផលប្រយោជន៍នៃការចូលរួមក្រុមសន្សំនេះ។ យោងតាមសេចក្ដីសម្រេចចិត្តរបស់សមាជិកក្រុមបានឯកភាពគ្នាថាប្រាក់ដែលសន្សំ មានទាំងដើម និងការប្រាក់នេះ មិនទាន់ធ្វើការបែងចែងគ្នាទៅវិញទេ ដោយពួកគេមានបំណងចង់សន្សំបន្តទៀតដើម្បីពង្រីកដើមទុនឲ្យបានច្រើន។ សមាជិកដែលបានខ្ចីប្រាក់នោះ បានយកទៅប្រកបមុខរបរដូចជា៖ ទិញអេតចាយ, ទិញជីបាចស្រូវ , ថ្នាំសម្រាប់បាញ់សម្លាប់សត្វល្អិតស៊ីឫកាត់ស្រូវ ,និងលក់ចាបហួយ។ ពីព្រោះស្ថានភាពដីនៅតំបន់នេះមិនអំណោយផលដល់ការដាំបន្លែ ណាមួយសមាជិកក្រុមមិនមានដីគ្រប់គ្រាន់ដើម្បីដាំដំណាំ ឫក៏ចញ្ចឹមសត្វទេ មានតែធ្វើស្រែនិងធ្វើអាជីវកម្មជួញដូរពីព្រោះតំនេះនៅជិតព្រំប្រទល់ប្រទេសកម្ពុជា និងវៀតណាមភាគខាងត្បូងប្រទេស។*តាមសម្ដីរបស់បងស្រី សុខ សីនមានអាយុ៣០ឆ្នាំ។*

